**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

លេខ ៨៦៨ អយក.ប្រក

ចូល លេខៈ ៧៩៥

ថ្ងៃទី២៧ ខែ០៥ ឆ្នាំ២០២១

# ប្រកាស

## ស្តីពី

## ការបង្កើតដេប៉ាតឺម៉ង់ថ្មី មុខជំនាញថ្មី នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

* * * * *

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអប់រំ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញ អនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញ អនុក្រឹត្យលេខ ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- បានឃើញ អនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញ ប្រកាសលេខ ១៧៥៣ អយក.ប្រក ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មហាវិទ្យាល័យវិស្វកម្ម មហាវិទ្យាល័យសិក្សាអភិវឌ្ឍន៍ និងមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
- បានឃើញ ប្រកាសលេខ ១៤៣៥ អយក.ប្រក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីលក្ខខណ្ឌ និងលក្ខណវិនិច្ឆ័យលម្អិត សម្រាប់ការបង្កើតគ្រឹះស្ថានឧត្តមសិក្សា
- តាមសំណើរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

## ស ម្រេ ច

**ប្រការ ១.**_

អនុញ្ញាតឱ្យ**សាកលវិទ្យាល័យភូមិន្ទភ្នំពេញ** បង្កើតដេប៉ាតឺម៉ង់ថ្មី មុខជំនាញថ្មី កម្រិតបរិញ្ញាបត្រ ស្ថិតក្រោម**មហាវិទ្យាល័យសិក្សាអភិវឌ្ឍន៍** (Faculty of Development Studies)ដែលមានស្រាប់ ដូចខាងក្រោម៖

- **ដេប៉ាតឺម៉ង់ នគរូបនីយកម្ម និងអភិវឌ្ឍន៍ក្រុងដោយចីរភាព** ( Department of Sustainable Urban Planning and Development )
  - មុខជំនាញ នគរូបនីយកម្ម និងអភិវឌ្ឍន៍ក្រុងដោយចីរភាព ( Sustainable Urban Planning and Development )។

**ប្រការ ២.**_

សាកលវិទ្យាធិការនៃ**សាកលវិទ្យាល័យភូមិន្ទភ្នំពេញ** មានភារកិច្ច៖

- រៀបចំកម្មវិធីសិក្សាលម្អិតឱ្យស្របតាមលក្ខខណ្ឌ និងបទប្បញ្ញត្តិនៃក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា ដើម្បីសុំការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា
- រៀបចំតួនាទីនិងភារកិច្ច រចនាសម្ព័ន្ធគ្រប់គ្រង និងវិធានផ្ទៃក្នុងសម្រាប់ការគ្រប់គ្រងការសិក្សាសម្រាប់ដេប៉ាតឺម៉ង់ថ្មីខាងលើ ឱ្យមានគុណភាពស្របតាមគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា
- អនុវត្តតាមបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំណត់លើសកម្មភាពនៃការធានាគុណភាពអប់រំផ្ទៃក្នុងនៅឧត្តមសិក្សា
- រៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីការងារបណ្តុះបណ្តាលមកនាយកដ្ឋានឧត្តមសិក្សានៅក្រោយដំណាច់ឆមាសទី២ រយៈពេល២ខែ។

**ប្រការ ៣.**_

និស្សិតដែលរៀនចប់កម្មវិធីសិក្សា និងទទួលបានជោគជ័យក្នុងការបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្របរិញ្ញាបត្រ តាមមុខជំនាញដែលបានសិក្សា។ សញ្ញាបត្រនេះផ្តល់ឱ្យដោយ**សាកលវិទ្យាល័យភូមិន្ទភ្នំពេញ** ដោយផ្អែកលើបញ្ជីឈ្មោះនិស្សិតបញ្ចប់ការសិក្សាជាប់ជាស្ថាពរ ដែលមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ ៤.**_

អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានឧត្តមសិក្សា ប្រធានអង្គភាពពាក់ព័ន្ធ និងសាកលវិទ្យាធិការនៃ**សាកលវិទ្យាល័យភូមិន្ទភ្នំពេញ** ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ៣រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០២២

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
-ក្រុមប្រឹក្សាសាកលវិទ្យាធិការនៃកម្ពុជា
«ដើម្បីជ្រាបជាព័ត៌មាន»
-ដូចប្រការ៤ «ដើម្បីអនុវត្ត»
-កាលប្បវត្តិ
-ឯកសារ នាយកដ្ឋានឧត្តមសិក្សា